ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង សម្រាប់អនុវត្តភាតព្វកិច្ច និងការសន្យារបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ១១៩៨ / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញសេចក្តីសម្រេចលេខ ៣០ សសរ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំង និងដំណើរប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលការងារជាមួយអង្គការពាណិជ្ជកម្មពិភពលោក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១** : ត្រូវបានបង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងមួយ សម្រាប់អនុវត្តភាតព្វកិច្ច និងការសន្យារបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- ឯកឧត្តម ចាន់ សុវសំគ្គិ | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣-ឯកឧត្តម | អ៊ុច បូរិទ្ធ | រដ្ឋលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

**ទីស្តីការគណៈរដ្ឋមន្ត្រី**

| | | | |
|---|---|---|---|
| ៤-ឯកឧត្តម | សេង លឹមនៅ | រដ្ឋលេខាធិការ | សមាជិក |
| ៥-ឯកឧត្តមបណ្ឌិត | ជា វ៉ាន់ដេត | នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ចាប សុថារិទ្ធិ | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី | សមាជិក |
| ៧-លោក | តឹកឡើត សំរេច | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី | សមាជិក |

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

| | | | |
|---|---|---|---|
| ៨- ឯកឧត្តម | ហែម សារឹម | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី | សមាជិក |
| ៩- លោក | អេង ហ៊ីន | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១០-លោក | ស៊ុន សួន | ប្រធាននាយកដ្ឋានអង្គការអន្តរជាតិ | សមាជិក |

**ក្រសួងពាណិជ្ជកម្ម**

| | | | |
|---|---|---|---|
| ១១- ឯកឧត្តម | ម៉ៅ ថូរ៉ា | អនុរដ្ឋលេខាធិការ | សមាជិក |
| ១២- ឯកឧត្តម | ឈូន ដារ៉ា | អគ្គនាយកបច្ចេកទេស | សមាជិក |
| ១៣- លោក | សុខ សុតាំត្រា | អគ្គនាយករងបច្ចេកទេស | សមាជិក |
| ១៤- លោក | ពេជ ឫទ្ធី | អគ្គនាយករងបច្ចេកទេស | សមាជិក |
| ១៥- លោក | ម៉ក់ ពេជ្ររិទ្ធ | ប្រធាននាយកដ្ឋានកាំកុងត្រូល | សមាជិក |
| ១៦- លោក | ស៊ាង ថៃ | ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ | សមាជិក |
| ១៧- លោក | មាន សុគា | ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | សមាជិក |
| ១៨- លោក | អ៊ា រតសាន | ប្រធានប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |
| ១៩- លោក | ហូ សារ៉ាន់ | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ២០- លោក | ជួន ទន | ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស | សមាជិក |
| ២១- លោក | អ៊ុន ម៉ុនថា | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស | សមាជិក |
| ២២- លោក | ម៉ែន សុទិជាតិ | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |
| ២៣- លោក | ឈុប សោភ័ណតារា | អនុប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ | សមាជិក |
| ២៤- លោក | ឌិត រិទ្ធិពល | ប្រធានការិយាល័យអង្គការពាណិជ្ជកម្មពិភពលោក | សមាជិក |

**ក្រសួងមហាផ្ទៃ**

២៥- ឯកឧត្តម ទី ចំនួនផល អនុរដ្ឋលេខាធិការ សមាជិក

២៦- ឯកឧត្តម សក់ សេដ្ឋា អគ្គនាយករដ្ឋបាល សមាជិក

២៧- ឧត្តមសេនីយ៍ត្រី កែវ ចណ្ណាថន អនុប្រធានទី ១ការិយាល័យកណ្ដាលនគរបាលអន្តរជាតិ សមាជិក

**ក្រសួងការពារជាតិ**

២៨- ឯកឧត្តម ជុំ សម្បុង អនុរដ្ឋលេខាធិការ សមាជិក

២៩- ឯកឧត្តមឧត្តមសេនីយ៍ឯក ទេព ម៉ុនឡាយ អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ សមាជិក

៣០- ឯកឧត្តមឧត្តមសេនីយ៍ទោ ម៉ម សុផាត នាយក នាយកដ្ឋាននីតិកម្ម សមាជិក

៣១- ឯកឧត្តមឧត្តមសេនីយ៍ត្រី រស់ ផន នាយករង នាយកដ្ឋាននយោបាយ និងផែនការ សមាជិក

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

៣២- ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការទី ១ សមាជិក

៣៣- ឯកឧត្តម ស្រ៊ុន តារា អនុរដ្ឋលេខាធិការ សមាជិក

៣៤- លោក អ៊ុយ សម្បត្តិ ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន សមាជិក

៣៥- លោក គុណ ញឹម នាយករងទីចាត់ការគយ និងរដ្ឋាករ សមាជិក

៣៦- លោក អ៊ុំ ស៊ីហា អនុប្រធានទី ១ នាយកដ្ឋានពន្ធដារ សមាជិក

៣៧- លោក គីម សុគៈ អនុប្រធាននាយកដ្ឋានពន្ធដារ សមាជិក

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

៣៨- ឯកឧត្តម ចំនួន តុងអ៊ីច រដ្ឋលេខាធិការ សមាជិក

៣៩- ឯកឧត្តម គុំ សារ៉ុន អគ្គនាយក សមាជិក

៤០- លោក ម៉ែន ឌុច ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម សមាជិក

៤១- លោក ខួត សាវ៉ាឌុច ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

**ក្រសួងអភិវឌ្ឍន៍ជនបទ**

៤២- ឯកឧត្តម សួស គង់ រដ្ឋលេខាធិការ សមាជិក

៤៣- ឯកឧត្តម សៅ ជីវ័ន្ត អនុរដ្ឋលេខាធិការ សមាជិក

| | | | |
|---|---|---|---|
| ៤៤- លោក | ផាន់ សារឿន | ប្រធាននាយកដ្ឋានសេដ្ឋកិច្ចជនបទ | សមាជិក |
| ៤៥- លោក | ឡុច មៀមដែត | ប្រធានការិយាល័យទំនាក់ទំនងទីផ្សារ | សមាជិក |

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

| | | | |
|---|---|---|---|
| ៤៦- ឯកឧត្តម | អ៊ិត ប្រាំង | រដ្ឋលេខាធិការ | សមាជិក |
| ៤៧- លោក | សាត សមុទ្រ | អគ្គនាយករង | សមាជិក |
| ៤៨- លោក | ពីង ស៊ីវឡាយ | ប្រធាននាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា | សមាជិក |
| ៤៩- លោក | ទ័ត ទិមុល | ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម | សមាជិក |

**ក្រសួងផែនការ**

| | | | |
|---|---|---|---|
| ៥០- ឯកឧត្តម | ឆឹង ចំរើន | រដ្ឋលេខាធិការ | សមាជិក |
| ៥១- ឯកឧត្តម | ខួន ថាវរៈ | អគ្គនាយក | សមាជិក |
| ៥២- លោក | សួន សុខឃីម | ប្រធាននាយកដ្ឋាន | សមាជិក |
| ៥៣- លោក | ហួយ សិទ្ធិគុណ | អនុប្រធាននាយកដ្ឋាន | សមាជិក |

**ក្រសួងអប់រំ យុវជន និងកីឡា**

| | | | |
|---|---|---|---|
| ៥៤- ឯកឧត្តម | ឆៀ ថេន | រដ្ឋលេខាធិការ | សមាជិក |
| ៥៥- ឯកឧត្តម | តើ ណៃលាង | អគ្គនាយកអប់រំ | សមាជិក |
| ៥៦- លោក | សំ សើររតន៍ | ប្រធាននាយកដ្ឋានផែនការ | សមាជិក |
| ៥៧- លោក | លី សិទ្ធិ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| ៥៨- លោក | ថោង បូរ៉ាន់ | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៥៩- លោក | រត្ន័ សុខា | ប្រធាននាយកដ្ឋានឧត្តមសិក្សា | សមាជិក |

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

| | | | |
|---|---|---|---|
| ៦០- ឯកឧត្តម | សយ ស៊ីផុន | រដ្ឋលេខាធិការ | សមាជិក |
| ៦១- ឯកឧត្តម | កែវ បុររន្ត | អគ្គនាយកបច្ចេកទេស | សមាជិក |
| ៦២- លោក | លឹម អែលឡូរ៉ាដូ | ប្រធាននាយកដ្ឋានផែនការ សរុប និងស្ថិតិ | សមាជិក |
| ៦៣- លោក | ញៀប ចាន់ណោ | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

| | | | |
|---|---|---|---|
| ៦៤- ឯកឧត្តម | ម៉ម សូផាណា | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦៥- លោក | ហ៊ុយ ណារ៉ា | អគ្គនាយករង | សមាជិក |
| ៦៦- លោក | ហ៊ុយ ផាប់ | អនុប្រធាននាយកដ្ឋានអភិរក្សសុរិយោដី | សមាជិក |

**ក្រសួងបរិស្ថាន**

| | | | |
|---|---|---|---|
| ៦៧- ឯកឧត្តម | ខុន សំនួន | រដ្ឋលេខាធិការ | សមាជិក |
| ៦៨- ឯកឧត្តម | ឡុញ ម៉ារិល | អគ្គនាយកបច្ចេកទេស | សមាជិក |
| ៦៩- លោក | ហេង ណារ៉េត | ប្រធាននាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន | សមាជិក |

**ក្រសួងធនធានទឹក និងឧតុនិយម**

| | | | |
|---|---|---|---|
| ៧០- ឯកឧត្តម | ទេង សាខុន | រដ្ឋលេខាធិការ | សមាជិក |
| ៧១- លោក | ផេង តារា | ប្រធានគ្រប់គ្រង និងអភិរក្សធនធានទឹក | សមាជិក |
| ៧២- លោក | ឈា ប៊ុនរិទ្ធ | អនុប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**ក្រសួងព័ត៌មាន**

| | | | |
|---|---|---|---|
| ៧៣- ឯកឧត្តម | អ៊ី លន់ | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧៤- លោក | រស់ រតនា | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**ក្រសួងយុត្តិធម៌**

| | | | |
|---|---|---|---|
| ៧៥- ឯកឧត្តម | ចាន់ ហួន | រដ្ឋលេខាធិការ | សមាជិក |
| ៧៦- លោក | ម៉ែន ពេជ្រសាលី | ប្រធាននាយកដ្ឋានកិច្ចការអន្តរជាតិ | សមាជិក |
| ៧៧- លោក | ញៀម វណ្ណរ៉េត | អនុប្រធាននាយកដ្ឋានកិច្ចការអន្តរជាតិ | សមាជិក |
| ៧៨- លោក | ស៊ុំ សារ៉ាត់ | ប្រធានការិយាល័យ | សមាជិក |

**ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

| | | | |
|---|---|---|---|
| ៧៩- ឯកឧត្តម | ឆេង សារឿន | រដ្ឋលេខាធិការ | សមាជិក |
| ៨០- ឯកឧត្តម | ពូ ដារ៉ានី | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨១- លោក | តៅ សាន់ឌី | មន្ត្រី | សមាជិក |

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

| | | | |
|---|---|---|---|
| ៨២-ឯកឧត្តម | ជិន ប៊ុនស៊ាន | រដ្ឋលេខាធិការ | សមាជិក |
| ៨៣- ឯកឧត្តម | មាស ម៉ូ | អគ្គនាយក | សមាជិក |
| ៨៤- លោកស្រី | ឡេ ម៉ាយគៀង | អគ្គនាយករងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៨៥- លោក | ត្រឹង ឌូម៉ា | អនុប្រធាននាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ | សមាជិក |

**ក្រសួងសុខាភិបាល**

| | | | |
|---|---|---|---|
| ៨៦- ឯកឧត្តម | អ៊ឹង គីរុន | រដ្ឋលេខាធិការ | សមាជិក |
| ៨៧- ឯកឧត្តម | សុខ ផេង | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨៨- លោក | ជូ យិនស៊ីម | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨៩- លោក | ជី មានហៀ | អគ្គនាយករងបច្ចេកទេស | សមាជិក |
| ៩០- លោក | ច្រឹង សុខន | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៩១- លោក | ឈៀង ផារណា | អនុប្រធាននាយកដ្ឋានឱសថ-ចំណីអាហារ | សមាជិក |
| ៩២- លោក | ហេង ហួត | ប្រធានការិយាល័យនិយ័តកម្មឱសថ | សមាជិក |

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

| | | | |
|---|---|---|---|
| ៩៣- ឯកឧត្តម | កែប ជន | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩៤- លោក | ចាន់ តារា | អគ្គនាយករង នៃអគ្គនាយកដ្ឋានដឹកជញ្ជូន | សមាជិក |
| ៩៥- លោក | ម៉ក់ ស៊ីដេត | ប្រធាននាយកដ្ឋាននាវាសមុទ្រ | សមាជិក |
| ៩៦- លោក | សុខុម ទិរៈផល | ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក | សមាជិក |
| ៩៧- លោក | ស្រី សិរីវឌ្ឍន៍ | អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក | សមាជិក |
| ៩៨- លោក | ជាម សុវណ្ណនី | អនុប្រធាននាយកដ្ឋានផែនការ | សមាជិក |
| ៩៩- លោក | អៀង ទេងស៊ុន | នាយកអាជីវកម្មកំពង់ផែភ្នំពេញ | សមាជិក |
| ១០០-លោក | ពៅ ឡាធី | ប្រធានការិយាល័យនីតិកម្ម នៃនាយកដ្ឋានរដ្ឋបាល | សមាជិក |

**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

| | | | |
|---|---|---|---|
| ១០១-ឯកឧត្តម | សំរាំង កំសាន្ត | អនុរដ្ឋលេខាធិការ | សមាជិក |
| ១០២-ឯកឧត្តម | ស៊ឹម សារ៉ាក់ | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១០៣-លោក | អ៊ុន ធីម | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |

| | | | |
|---|---|---|---|
| ១០៤-លោក | លឹម យូសួ | អនុប្រធាននាយកដ្ឋាន | សមាជិក |

**ក្រសួងទេសចរណ៍**

| | | | |
|---|---|---|---|
| ១០៥-ឯកឧត្តម | ថោង ខុន | រដ្ឋលេខាធិការ | សមាជិក |
| ១០៦-លោក | ហោ សារុន | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១០៧-លោក | ឈុន ណារ៉ាត់ | អនុប្រធាននាយកដ្ឋានអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១០៨-លោក | សោម ម៉ិនណារ៉ាត | ប្រធានការិយាល័យអង្គការអន្តរជាតិ | សមាជិក |

**ក្រសួងធម្មការ និងសាសនា**

| | | | |
|---|---|---|---|
| ១០៩-ឯកឧត្តម | ឈឹម អឿម | រដ្ឋលេខាធិការ | សមាជិក |
| ១១០-ឯកឧត្តម | ហ៊ុំ គឹមថន | អនុរដ្ឋលេខាធិការ | សមាជិក |
| ១១១-លោក | ខួន ម៉ាន់ចន្ធី | នាយកពុទ្ធសាសនបណ្ឌិត្យ | សមាជិក |
| ១១២-លោក | អ៊ឹង សុភារិទ្ធ | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |

**ក្រសួងកិច្ចការនារី**

| | | | |
|---|---|---|---|
| ១១៣-លោកជំទាវ | អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រី | សមាជិក |
| ១១៤-លោកជំទាវ | កេត សំអាត | អនុរដ្ឋលេខាធិការ | សមាជិក |
| ១១៥-លោកស្រី | ម៉ិនឈិត មាសនា | ប្រធានការិយាល័យ | សមាជិក |

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

| | | | |
|---|---|---|---|
| ១១៦-ឯកឧត្តម | អ៊ុំ មាន | អនុរដ្ឋលេខាធិការ | សមាជិក |
| ១១៧-លោក | ហ៊ូ ឧត្តរី | អគ្គនាយករង | សមាជិក |
| ១១៨-លោក | ហួត ចាន់ធី | ប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១១៩-លោក | នី សេរីរិទ្ធ | នាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី | សមាជិក |

**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

| | | | |
|---|---|---|---|
| ១២០-លោក | នូ សុវណ្ណា | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ១២១-លោក | ខៀវ ចំនួម៉ិនធឿន | ប្រធាននាយកដ្ឋានក្របខ័ណ្ឌ | សមាជិក |

| | | | |
|---|---|---|---|
| ១២២-ឯកឧត្តម | កែវ សាផល | អនុរដ្ឋលេខាធិការ | សមាជិក |
| ១២៣-លោក | ស៊ិន ចាន់សេរីវុត្ថា | ប្រធាននាយកដ្ឋានផែនការនីតិកម្ម | សមាជិក |
| ១២៤-លោក | អ៊ិន ទីសាលភាព | អនុប្រធាននាយកដ្ឋានដឹកជញ្ជូន | សមាជិក |

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

| | | | |
|---|---|---|---|
| ១២៥-ឯកឧត្តម | សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១២៦-ឯកឧត្តម | សួន សិទ្ធី | អគ្គលេខាធិការរង ក.អ.ក និង គ.វ.ក | សមាជិក |
| ១២៧-ឯកឧត្តម | ជា វុទ្ធី | អគ្គលេខាធិការរងតំបន់សេដ្ឋកិច្ចពិសេស | សមាជិក |
| ១២៨-លោក | អន សុផាំណារ៉ា | ប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគ | សមាជិក |
| ១២៩-លោកស្រី | ដេង សុភាព | អនុប្រធាននាយកដ្ឋានសម្របសម្រួលកិច្ចការអន្តរក្រសួង | សមាជិក |

**ធនាគារជាតិនៃកម្ពុជា**

| | | | |
|---|---|---|---|
| ១៣០-លោកជំទាវ | តាល់ ណែរអ៊ីម | អគ្គនាយក | សមាជិក |
| ១៣១-លោកស្រី | ខូន សុខា | ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ | សមាជិក |

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

| | | | |
|---|---|---|---|
| ១៣២-មេធាវី | នូ ធេរីរិទ្ធ | សមាជិកក្រុមប្រឹក្សាគណៈមេធាវី | សមាជិក |
| ១៣៣-មេធាវី | ហែម ហ្វូណារិទ្ធ | សមាជិកគណៈមេធាវី | សមាជិក |

ក្នុងករណីមន្ត្រី ដែលជាសមាជិកគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង មិនអាចបំពេញការងាររបស់ខ្លួនបាន ដោយសារមូលហេតុផ្សេងៗ សាមីក្រសួងត្រូវជ្រើសរើសមន្ត្រី ដែលមានឋានៈ និងបទពិសោធន៍ប្រហាក់ប្រហែលមកជំនួសវិញ ដោយគ្រាន់តែធ្វើលិខិតបញ្ជូនមកប្រធានគណៈកម្មាធិការ ដើម្បីសុំប្តូរ និងចម្លងជូនដំណឹងទៅទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ២** : គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង មានភារកិច្ចដូចតទៅ :

- ធានាអនុវត្តឱ្យបានសម្រេចនូវកម្មវិធីការងាររបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធទៅនឹងអង្គការពាណិជ្ជកម្មពិភពលោក ដោយធ្វើការណែនាំ និងត្រួតពិនិត្យដំណើរការរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការបំពេញភារកិច្ចតាមកម្មវិធីការងាររបស់ខ្លួន និងរាយការណ៍ជូនគណៈរដ្ឋមន្ត្រីជាប្រចាំ យ៉ាងហោចណាស់រៀងរាល់ ៦ ខែ ម្តង។
- ណែនាំឱ្យមានការរៀបចំផែនការសកម្មភាពសម្រាប់តាមក្រសួង-ស្ថាប័នពាក់ព័ន្ធ អនុវត្តកាតព្វកិច្ចឱ្យស្របតាមការសន្យារបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក។

- ពិនិត្យឡើងវិញនូវភាពស្របគ្នាជាមួយនឹងវិធានទាំងឡាយ របស់អង្គការពាណិជ្ជកម្មពិភពលោកនូវលិខិតបទដ្ឋានច្បាប់ ដែលមានស្រាប់ និងដែលកំពុងព្រាង ហើយរាយការណ៍ជូនគណៈរដ្ឋមន្ត្រី អំពីលិខិតបទដ្ឋានច្បាប់ទាំងឡាយណា ដែលមិនស្របទៅនឹងវិធានរបស់អង្គការពិភពលោក ។
- រៀបចំឯកសារវិភាគគោលនយោបាយលើបញ្ហាទាំងឡាយ ដែលកំពុងពិភាក្សា និងចរចានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក សម្រាប់ដាក់ជូនគណៈរដ្ឋមន្ត្រីធ្វើការពិចារណា ដើម្បីកំណត់ជំហរចរចារបស់កម្ពុជា នៅក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ។
- ណែនាំ និងត្រួតពិនិត្យ ការធ្វើសេចក្តីជូនព័ត៌មាន (Notification) របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ នូវលិខិតបទដ្ឋានច្បាប់ និងបទប្បញ្ញត្តិនានា តាមការតម្រូវនៃកិច្ចព្រមព្រៀង ជូនលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក។ តាមរយៈលេខាធិការដ្ឋានរបស់ខ្លួន គណៈកម្មការនេះត្រូវផ្តល់សេវាជាចំណុចប្រសព្វ (Focal Point) សម្រាប់បញ្ជូនសេចក្តីជូនដំណឹងអំពីលិខិតបទដ្ឋានបច្ចេកទេស និងច្បាប់ ជូនលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក តាមរយៈស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស និងតាមច្រកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
- ផ្តល់នូវការគាំពារយ៉ាងសកម្ម និងឱ្យមានប្រសិទ្ធភាពដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការធានានូវការស្វែងរក និងផ្តល់ជំនួយបច្ចេកទេសចាំបាច់ សម្រេចបំពេញការងារតាមកម្មវិធី និងតាមការចាំបាច់។
- រាយការណ៍ជូនរាជរដ្ឋាភិបាលជាប្រចាំ និងតាមការចាំបាច់អំពីលទ្ធផលនៃការចរចា និងសុំយោបល់សម្រេចលើការងារ ដែលហួសសមត្ថកិច្ចរបស់ខ្លួន។

មាត្រា ៣ : គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង អាចប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម លើរាល់លិខិតស្នាមផ្លូវការ និងត្រូវរៀបចំទីកាសម្រាប់ការងាររបស់ខ្លួន ដែលធ្វើជាមួយនឹងគណនីរបស់ក្រសួងពាណិជ្ជកម្ម។ សមាជិកគណៈកម្មាធិការសម្របសម្រួលនេះត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

មាត្រា ៤ : គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង ត្រូវរៀបចំក្រុមចរចាអន្តរក្រសួងសម្រាប់ចូលរួមចរចា ជាមួយសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងចូលរួមដោះស្រាយវិវាទនានា ដែលកើតមានក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក។

ប្រធានគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង អាចអញ្ជើញមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញពីក្រសួងពាក់ព័ន្ធ មកចូលរួមជាសមាជិកបន្ថែម និងអាចបង្កើតក្រុមការងារជំនាញផ្សេងទៀត ឱ្យស្ថិតនៅក្រោមឱវាទរបស់ខ្លួន ប្រសិនជាយល់ឃើញថាចាំបាច់ ។

**មាត្រា ៥ :** គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង ត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួន ជូនទៅអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងពាណិជ្ជកម្មទាក់ទងនឹងវិនិយោគ ដើម្បីទទួលយកការណែនាំ។

**មាត្រា ៦ :** គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងត្រូវមានលេខាធិការដ្ឋាន ដែលមានទីស្នាក់ការនៅទីស្តីការក្រសួងពាណិជ្ជកម្ម។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយលេខាធិការមួយរូប និងជំនួយការមួយចំនួនតាមការចាំបាច់។ មន្ត្រីជំនួយការ ក្នុងលេខាធិការដ្ឋាននេះ អាចរើសចេញពីមន្ត្រីក្របខ័ណ្ឌរបស់ក្រសួងពាណិជ្ជកម្ម ឬអាចជាមន្ត្រីក្របខ័ណ្ឌ ដែលស្នើសុំពីក្រសួងស្ថាប័ននានា របស់រាជរដ្ឋាភិបាល។

**មាត្រា ៧ :** លេខាធិការដ្ឋាន ផ្តល់ជូននូវការគាំពារផ្នែកបច្ចេកទេស ទៅឱ្យសកម្មភាពទាំងអស់របស់គណៈកម្មាធិការ ហើយមានភារកិច្ចពិសេស ដូចខាងក្រោម :

១- រៀបចំរបៀបវារៈ និងឯកសារទាំងអស់ សម្រាប់កិច្ចប្រជុំរបស់គណៈកម្មាធិការ និងអនុវត្តបន្តនូវភារកិច្ចផ្សេងៗទៀត ដែលចាំបាច់ក្នុងការរៀបចំកិច្ចប្រជុំទាំងនោះ។

២- រៀបចំរបាយការណ៍ពីលទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ និងរៀបចំឯកសារផ្សេងៗទៀត ដែលតម្រូវឱ្យមានការសម្រេចចិត្តពីគណៈកម្មាធិការ។

៣- ធានានូវការបញ្ជូនព័ត៌មានទាំងអស់ ទាក់ទងទៅនឹងសកម្មភាពរបស់គណៈកម្មាធិការ ទៅឱ្យសមាជិកគណៈកម្មាធិការទាំងអស់។

៤- ផ្តល់នូវការគាំទ្រគ្រប់បែបយ៉ាងចំពោះក្រុមអ្នកចរចា ឬអនុគណៈកម្មាធិការ ដែលបានបង្កើតឡើងដោយគណៈកម្មាធិការសម្របសម្រួលនេះ។

៥- ទទួលអនុវត្តបន្តនូវភារកិច្ចផ្សេងៗទៀត ដែលស្នើឡើងដោយគណៈកម្មាធិការសម្របសម្រួល។

**មាត្រា ៨ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ